# ពេលដែលត្រូវ ភ្ញាក់ខ្លួន




ពេលដែលត្រូវ ភ្ញាក់ខ្លួន

នៅថ្ងៃទី ២៩ កក្កដា ឆ្នាំ ២០១៨, បននៅភ្នំពេញ បានប្រព្រឹត្ត នូវបទឧក្រិដ្ឋអាក្រក់មួយ ដែលខ្លួន ទុកជាមហាជោគជ័យ ប្រឆាំងនឹង លទ្ធិប្រជាធិបតេយ្យ។ បទឧក្រិដ្ឋនេះ ប្រមូល នូវគ្រប់ទង្វើគួរអោយខ្ពើម គឺ អំពើក្បត់ជាតិ មាននៅក្នុងទស្សនៈ, ការបង់ពាក្យសត្យ, ហនកម្ម មាននៅក្នុងការអនុវត្តន៍ និង ឃាតកម្ម មាននៅក្នុងការប្រយុទ្ធ, ការដណ្ដើមយកធនធាន និង លួចប្លន់ មាននៅក្នុងជ័យជំនះ។ ដូច្នោះ បនភ្នំពេញ នាំតាមខ្លួនជាចិរកាល នូវឧក្រិដ្ឋកម្មនេះ ព្រោះវាជាសារជាតិ នៃខ្លួន។ បនភ្នំពេញ តែងតែលើកយកពាក្យសន្តិភាព មកធ្វើជាមូលដ្ឋាន នៃសមិទ្ធិកម្ម របស់ខ្លួន តែនៅក្នុងសន្តិភាពនេះ ស្រុកខ្មែរក្លាយជាទឹកដីបំណុល របស់ខ្លួន ចំពោះយៀកណាម ហើយត្រូវសងជាវត្ថុ ដូចយ៉ាង ការអនុញ្ញាតអោយជនជាតិយួនច្រើនក្រៃលែង ចូលមករស់នៅតាមសេរី និង កាត់ដីមួយចំណែក ប្រគល់អោយយៀកណាម។ ដូច្នោះ សមតានៃសន្តិភាពវិសមធម៌នេះ វាមានមូលដ្ឋាន ជាទំនាស់នឹងប្រយោជន៍ នៃប្រជាជាតិខ្មែរ។

ត្រូវជនខ្មែរស្លូតត្រង់គ្រប់មជ្ឈដ្ឋាន ភ្ញាក់ខ្លួនថា ការបំរើ និង គាំទ្រ ចំពោះបនភ្នំពេញ មិនមែនជាកិច្ចបំរើជាតិនោះទេ, ផ្ទុយ

## ពេលដែលត្រូវ ភ្ញាក់ខ្លួន

ទៅវិញ វាជា អ្នកបំរើបនចោរប្លន់។ បើខ្មែរយល់ឃើញដូច្នោះ ត្រូវនាំគ្នា ប្រញាប់ប្រញាល ទោះបីគ្មានសេចក្ដីក្លាហានកាន់អាវុធ ក៏ដាស់ នូវសតិសម្បជញ្ញៈជាតិនិយមខ្លួន អោយភ្ញាក់ឡើង ព្រោះវាជាពេលវេលាអាចនឹងប្រមូលបាន នូវសិទ្ធិជាពលរដ្ឋ, ច្បាប់ជាតិ និង អន្តរជាតិ, សុភនិច្ឆ័យ, សមធម៌, យុត្តិធម៌, ក្រងជាអាវុធអហិង្សា នៅក្នុងទឹកចិត្ត ជាពលរដ្ឋ ហ៊ានទទួលខុសត្រូវ លើជោគវាសនាខ្លួន ដើម្បីការពារ ជាចាំបាច់ នូវប្រយោជន៍ នៃប្រជាជាតិខ្មែរ។

កុំនាំគ្នានៅយល់ច្រឡំថានៅស្រុកខ្មែរសព្វថ្ងៃមាន វូបសន្ត ឬភាពស្ងៀមស្ងាត់ សំរាប់ការរស់នៅ។ ឧមាដែលបញ្ឆោតនេះឯង ដែលលាក់បាំង នូវអំពើហិង្សាគ្រប់បែបយ៉ាងនៅក្នុងសង្គម ដូចយ៉ាង គ្មាននីតិរដ្ឋ គ្មានសេរីភាព គ្មានសមភាព គ្មានយុត្តិធម៌, គ្មានភាតរភាព...។ល។ កង្វះទាំងឡាយនេះឯង វាជាគរុភាព សំរាប់ការរស់នៅ របស់ប្រជាពលរដ្ឋ។ ដូច្នេះ សន្តិភាពអន្ទងហៅ ដោយបនភ្នំពេញ វាជាសន្តិភាព ស្ថិតនៅក្នុងភាពជំមហិមា នៃឧបវាទ[1]។ ម្លោះហើយ ពេលនេះឯង ដែលខ្មែរគ្រប់ថ្នាក់សង្គម ត្រូវភ្ញាក់ខ្លួន ព្រោះ បើនាំគ្នានិទ្រា គឺប្រជាជាតិខ្មែរស្លាប់។ សម្រាន្តនៅផ្ទះ វាមិនអាចឈ្នះអំណាចផ្ដាច់ការ និងអាណានិគមយួនបានជាដាច់ខាត៕

[1] ការមើលងាយ។